# បទអន្តរាគមន៍

## ឯកឧត្តម គិត សេង អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
## ថ្លែងក្នុងសន្និបាតបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ២០០៩ និង
## លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០១០

*(រាជភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០)*

*សូមគោរព:* - *គណៈអធិបតី*
- *ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី*
- *ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក សមាជិកានៃអង្គសន្និបាត ជាទីមេត្រី*

*ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមក្នុងពិធីប្រារព្ធបើកសន្និបាតបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ២០០៩ និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០១០ នាពេលនេះ។ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះក្រសួងពាណិជ្ជ ដែលបានអនុញ្ញាតអោយខ្ញុំមានឱកាសបានជំរាបជូនអង្គសន្និបាតអំពីសមិទ្ធផលនានា ដែលក្រសួងកសិកម្ម រុក្ខា- ប្រមាញ់ និង នេសាទសំរេចបាននាឆ្នាំ២០០៩-២០១០ នេះ និងទិសដៅជាវិធានការដែលត្រូវបន្តទៅមុខមួយចំនួនទៀត។*

*ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី!*

*ឆ្នាំ ២០០៩ ជាឆ្នាំទី ២ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៤ នៃរដ្ឋសភាក្រោមចក្ខុវិស័យដ៏ឈ្លាសវៃប្រកបដោយភាពម៉ឺងម៉ាត់បំផុតរបស់* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** *នៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះការលើកស្ទួយវិស័យកសិកម្ម គឺជាមុំមួយដ៏សំខាន់សំរាប់ជំរុញនូវកំណើនសេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានជំរុញផលិតកម្មកសិកម្មតាមគ្រប់មុខព្រួញ ជាពិសេសការបង្កបង្កើនផលដំណាំយុទ្ធសាស្ត្រ មានជាអាទិ៍ ដំណាំស្រូវ កៅស៊ូ ដំណាំកសិ-ឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដែលមិនត្រឹមតែអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុកប៉ុណ្ណោះទេ គឺថែមទាំងនៅសល់សម្រាប់ធ្វើការនាំចេញទៀតផង។*

ជាង ២,៣៣ លានហិកតា ដែលទទួលបានទិន្នផលមធ្យមចំនួន ២,៦២ តោន/ ហិកតា និងបរិមាណផលសរុបជាង ៦ លានតោន។ ជាមួយនេះ ស្រូវរដូវប្រាំងឆ្នាំ ២០០៩-២០១០ នៅលើផ្ទៃដី០,៣៨ លានហិកតា ក្នុងទិន្នផលជាមធ្យម ៤,១២ តោន/ ហិកតា ដោយទទួលបានបរិមាណផលសរុបជាង ១,៥៨ លានតោន។ សរុបទាំងស្រូវរដូវវស្សា និងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុបជាង ២,៧១ លានហិកតា ដោយទទួលបានបរិមាណផលសរុប ៧,៥៨ លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ២,៨៣ តោន/ ហិកតា។ ដូចនេះតុល្យភាពស្បៀង យើងនៅសល់អង្ករជាង ២,២៤ លានតោន គិតជាស្រូវ ៣,៥០លានតោន។ ដោយឡែក ដំណាំរួមផ្សំ យើងអនុវត្តបានប្រមាណ ៤៤៨,០០០ ហិកតា កើនលើសឆ្នាំមុនចំនួន ៣៩,០០០ ហិកតា និងទទួលបាននូវបរិមាណផលសរុបជាង ៥ លានតោន ដែលក្នុងនោះមានដំណាំដំឡូងមី ដំឡូងជ្វា សណ្តែកបាយ បន្លែគ្រប់មុខ។ល។ ចំពោះដំណាំឧស្សាហកម្ម ដូចជាសណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ ថ្នាំជក់ អនុវត្តដាំដុះបានចំនួន ១៧៩,០០០ហិកតា លើសឆ្នាំមុន ៣២ ហិកតា និងបរិមាណផលសរុបប្រមាណ ៦០០,០០០ តោន។ ម្យ៉ាងវិញទៀត ដំណាំកៅស៊ូ នាពេលបច្ចុប្បន្ននេះ ផ្ទៃដីដាំដុះសរុបមានចំនួន ១០៧,៩០០ ហិកតា កើនឡើង ៣១% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ឬស្មើនឹង ៧២% នៃផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៥។

ការងារផលិតកម្ម និងបសុព្យាបាល ជាអនុវិស័យដ៏សំខាន់មួយដែលបានរួមចំណែកបង្កើតការងារ និងបង្កើនប្រាក់ចំណូលដល់គ្រួសារកសិករជនបទ មានកំណើនគួរកត់សំគាល់។ ជាក់ស្តែង ផលិតកម្មគោ-ក្របីមានចំនួន ៤,៣ លានក្បាលកើនលើសឆ្នាំមុនចំនួន ២,៦៧%។ ផលិតកម្មជ្រូកមាន ២,១២ លានក្បាល និងសត្វស្លាបមានចំនួន ២០,១៩ លានក្បាល កើនលើសឆ្នាំមុន ១៦%។ ដោយឡែក វិស័យជលផល និងវិស័យព្រៃឈើបានដំណើការការងារកែទម្រង់យ៉ាងសកម្ម និងប្រកបដោយជោគជ័យ ជាមួយនឹងភាពរីកចំរើនគួរជាទីមោទនៈ ក្នុងផ្នែកវារីវប្បកម្ម និងការស្តារព្រៃឈើឡើងវិញ។

ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី!

និយាយជារួម ការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានទទួលជោគជ័យជាលទ្ធផលល្អប្រសើរ ជាពិសេសលើបរិមាណផលិតផលស្រូវ ដែលមានកំណើន ៥.៧២% លើសឆ្នាំមុន ជាមួយគ្នានេះកំណែទម្រង់លើវិស័យព្រៃឈើ និងជលផលក៏បានដំណើរការទៅមុខប្រកបដោយលទ្ធផលផ្លែផ្កា គួបផ្សំនឹងការផ្តល់នូវសេវាកម្មគាំទ្រ និងការផ្សព្វផ្សាយនូវបច្ចេកវិទ្យាមានសភាពកាន់តែសកម្ម និងជ្រៀតចូលបានកាន់តែជ្រៅចូលទៅក្នុងមជ្ឈដ្ឋានប្រជាកសិករ។ ការរីកចំរើនលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះ គឺជាលទ្ធផលនៃការខិតខំមិនចេះនឿយហត់របស់កសិករយើង ក្រោមការដឹកនាំដ៏ឧត្តុងឧត្តម និងភ្លឺស្វាងរបស់ **រាជរដ្ឋាភិបាលកម្ពុជា** ដែលមានស្ថាប័នជំនាញ និងស្ថាប័នពាក់ព័ន្ធជាសេនាធិការ ហើយជាមួយនេះក៏មានការរួមចំណែកពីបណ្តាដៃគូអភិវឌ្ឍន៍ផងដែរ ជាពិសេស គឺការផ្តល់នូវជំនួយ

បច្ចេកទេស និងហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់។ ជាការសន្និដ្ឋាន វិស័យកសិកម្ម បច្ចុប្បន្ននេះមានការអភិវឌ្ឍន៍ប្រកដដោយមោទនភាព ជាពិសេសគឺផលិតកម្មកសិកម្មកម្ពុជាបានឈានចូលដល់ដំណាក់កាលល្អបំផុតមួយ ក្នុងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងសមិទ្ធផលនានា ដូចដែលបានជម្រាបជូនអង្គសន្និបាតកន្លងមកនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក៏ជួបប្រទះនូវបញ្ហាលំបាកមួយចំនួនដែរ ដែលអាចចាំបាច់ត្រូវមានការចូលរួមដោះស្រាយជាប្រព័ន្ធពីស្ថាប័ន និងផ្នែកពាក់ព័ន្ធនានា ដើម្បីឈានដល់ការលើកកំពស់ និងពង្រឹងការងារផលិតកម្មកសិកម្ម ក៏ដូចជាការធ្វើពាណិជ្ជកម្មកសិកម្ម។ ការលំបាក និងដំណោះស្រាយរួមគ្នាទាំងនោះមាន:

- ការរួមគ្នាក្តាប់បាននូវស្ថិតិនៃការនាំចេញ និងនាំចូលផលិតផលកសិកម្ម
- ការប្រកួតប្រជែងរវាងផលិតកម្មក្នុងស្រុក ជាមួយផលិតផលនាំចូលពីបរទេស ដែលចាំបាច់គួរមានគោលការណ៍ជាយុទ្ធសាស្ត្រមួយក្នុងការលើកកំពស់ការផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុក និងកាត់បន្ថយនូវការនាំចូល ក្នុងបរិមាណច្រើនពីខាងក្រៅ
- ការប្រមូលផ្តុំធនធាន និងវិធានការផ្សេងទៀត ដែលគាំទ្រសហគ្រាសធំៗ មួយចំនួនតូច (ចំនួន ២ ឬ ៣សហគ្រាស) ដែលមានសមត្ថភាព និងបទពិសោធន៍ពាណិជ្ជកម្មដើម្បីប្រសិទ្ធភាពនៃការនាំចេញអង្ករកម្ពុជា ជាជាងការគាំទ្ររាយប៉ាយជាលក្ខណៈទូទៅ

ម្យ៉ាងវិញទៀត ក្នុងគោលដៅលើកកំពស់ដល់ការនាំចេញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមរយៈក្រុមការងារជម្រុញការនាំចេញផលិតផលកសិកម្ម បានរៀបចំនូវផែនការសកម្មភាពជម្រុញការនាំចេញតាមវិស័យសម្រាប់រយៈពេល ៥ ឆ្នាំ (២០០៩-២០១៣) ដោយអនុលោមទៅតាមយុទ្ធសាស្ត្រសមាហរណកម្មវិស័យពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧។ គោលគំនិតនៃ **ការបង្កើនការនាំចេញផលិតផលកសិកម្ម** គឺសំដៅទៅលើការជម្រុញការកែលំអរផលិតកម្មកសិកម្ម បង្កើនបរិមាណផលិតភាព គុណភាព និងសុវត្ថិភាពចំណីអាហារ ដែលកត្តាទាំងនេះ អាចជម្រុញអោយមានការផ្លាស់ប្តូរទម្លាប់នៃការងារកសិកម្មបែបយថាផល មកជាការធ្វើកសិកម្មបែបទំនើប។

ទន្ទឹមនឹងនេះដែរ ក្នុងគោលដៅជម្រុញការលើកកំពស់ផលិតភាព និងពិពិធកម្មកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បន្តការខិតខំ និងយកចិត្តទុកដាក់នូវយុទ្ធវិធីមួយចំនួន ដូចជា:

- ជម្រុញកសិ-ឧស្សាហកម្មអោយមានសន្ទុះខ្លាំងក្លា ដោយបង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសដៅពីការអភិវឌ្ឍន៍តាមបែប <u>វិបុលកម្ម</u> ទៅកាន់ការអភិវឌ្ឍន៍តាមបែប <u>ប្រពលវប្បកម្ម</u> ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ ធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល

- *ផ្តល់ជូនកសិករនូវបច្ចេកទេសសមស្រប អោយបានដល់ស្រទាប់កសិករគោលដៅនៅតាមមូលដ្ឋាន*
- *ពង្រឹង និងពង្រីក **សេវាផ្សព្វផ្សាយ**កសិកម្ម និងត្រូវតំរង់ទិសជ្រើសរើសក្រុមគោលដៅដែលត្រូវទទួលផល ជាពិសេស ការយកចិត្តទុកដាក់ដល់ក្រុមកសិករ ដែលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្ម ឬសហករណ៍កសិកម្ម*
- *ជម្រុញ និងបង្កើតនូវបរិយាកាសអនុគ្រោះអោយកាន់តែប្រសើរឡើងថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជនទាំងក្នុង និងក្រៅប្រទេស អោយចូលរួមក្នុងផលិតកម្មកសិកម្ម ជាពិសេសផលិតកម្មដំណាំកសិ-ឧស្សាហកម្ម និងស្វាគមន៍ចំពោះ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើត និងធានាអោយបាននូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករក្នុងដាំដុះ និងចិញ្ចឹមសត្វ*
- *ផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផលទីផ្សារក្នុងស្រុក ដោយយកចិត្តទុកដាក់ទៅលើការអនុវត្តប្រព័ន្ធ **ផលិតកម្មតាមកិច្ចសន្យា** និងជម្រុញការឈានចូលទីផ្សារពិភពលោក តាមរយៈការខិតខំប្រឹងប្រែងលើកកំពស់គុណភាពកសិផល អោយសមស្របទៅតាមស្តង់ដារអន្តរជាតិ។ល។*

*ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល បវរមហាប្រសើរ ជូនចំពោះឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល សូមទទួលបាននូវពរជ័យទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាងឃ្លាតឡើយ។ ជាពិសេសនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំខាល ឯកស័ក ពុទ្ធសករាជ ២៥៥៦ ដែលនឹងឈានចូលក្នុងពេលដ៏ខ្លីខាងមុខនេះ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធ និងទេវតាឆ្នាំថ្មីតាមបីបាច់ថែរក្សាឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រីអោយជួបប្រទះតែនឹងសេចក្តីសុខ សុខភាពល្អ និងជ័យជំនះគ្រប់ការកិច្ច។*

**សូមអរគុណ!**